សន្និសីទអន្តរជាតិស្តីពីរ៉ែរ៉ែអាជីវកម្មរ៉ែ

"ឱកាសសម្រាប់កម្ពុជា"

ភ្នំពេញ ថ្ងៃទី ២៦_២៧ ខែ ឧសភា ឆ្នាំ ២០១០

THE AUSTRALIAN NATIONAL UNIVERSITY

# កត្តាមនុស្សនៅក្នុងអាជីវកម្មរ៉ែ

## ទិដ្ឋភាពរួមមួយនៃបញ្ហានៅជុំវិញកម្មករ និងសហគមន៍

Kuntala Lahiri-Dutt

THE AUSTRALIAN NATIONAL UNIVERSITY

# សេចក្ដីសង្ខេបអំពីបទបង្ហាញ

- ទិដ្ឋភាពរួមមួយអំពីបញ្ហាមនុស្ស នៅក្នុងអាជីវកម្មរ៉ែ និងការអនុវត្តឈានមុខ
  - ការធ្វើអាជីវកម្មរ៉ែ និងសហគមន៍ - កត្តាខាងក្រៅ
  - ការធ្វើអាជីវកម្មរ៉ែ និងកម្មករ - កត្តាខាងក្នុង
  - ការធ្វើអាជីវកម្មរ៉ែ និងយេនឌ័រ - ស្ត្រី ជាកម្មករអណ្ដូងរ៉ែ - ផលប៉ះពាល់
- តើការធ្វើអាជីវកម្មរ៉ែជាអ្វី? តើមនុស្សទាំងនោះជាអ្នកណា?
- បង្ហាញពីរបៀបដែលចាត់ទុកប្រជាជនថាមិនមែនជាប្រភពនៃបញ្ហា ប៉ុន្តែជារតនៈសម្បត្តិនៅក្នុងអាជីវកម្មរ៉ែ
- ជំហាននានាដែលត្រូវអនុវត្ត នៅទូទាំងវដ្តនៃគម្រោងអាជីវកម្មរ៉ែ
- បរិបទនៃប្រទេសនេះ
- បង្ហាញធនធាននានា សម្រាប់ការពិគ្រោះយោបល់ទៅអនាគត

អាចប្រើប្រាស់ឯកសារទាំងមូល សម្រាប់ផ្ដល់ជាព័ត៌មានលំអិត

# ‘បន្ទុកធ្ងន់ធ្ងរជ្រួល’ ឬ រតនៈសម្បត្តិ?

តើប្រជាជន គឺជាបញ្ហាមួយនៃការអភិវឌ្ឍអណ្តូងរ៉ែមែនឬទេ? តើ “ការមិនយកចិត្តទុកដាក់ខាងសង្គម” អាចជាដំណោះស្រាយមួយដែរឬទេ?

## រឿងរ៉ាវនៅប៊ូហ្គែនវីល : ប៉ាពូញូហ្គីនេ ឆ្នាំ 1988

- “ក្រុមប្រឆាំងមួយ” ដោយសារពុំមានការទូទាត់សំណង ឬ ការហូរចូលយ៉ាងច្រើននៃសាច់ប្រាក់ មកក្នុងសហគមន៍នានា ដែលមិនប្រើប្រាស់សាច់ប្រាក់ ?
- ការប្រឆាំងដូចគ្នានេះ - គម្រោងភុលបារី នៅបង់ក្លាដែស ការទាញយករ៉ែបុកស៊ីតនៅភ្នំអូរីសា ប្រទេសឥណ្ឌា






# តើមានភស្តុតាងអ្វីខ្លះ?

## អាជីវកម្មរ៉ែ និងសេដ្ឋកិច្ចជាតិ

### ឥទ្ធិពលវិជ្ជមាន

- ផលចំណូលពីរ៉ែ – "ការទាញយកផលពីធនធាន"
- ការងារធ្វើ – ដោយផ្ទាល់ និងប្រយោល
- ហេដ្ឋារចនាសម្ព័ន្ធ សំណង់

### ឥទ្ធិពលអវិជ្ជមាន

- អាចធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចមានភាពយឺតយ៉ាវ – "បណ្តាសារធនធាន"
- បង្កឱ្យខូចខាតក្នុងវិស័យកសិកម្ម – "ជម្ងឺហូឡង់"
- បង្កើតទ្រព្យសម្បត្តិសម្រាប់តែមនុស្សមួយក្រុមតូច
- បង្កើតអំពើពុករលួយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលសំបូរធនធាន

# តើមានផលប៉ះពាល់អ្វីខ្លះ?

## អាជីវកម្មរ៉ែ និងប្រជាជននៅមូលដ្ឋាន

### ឥទ្ធិពលវិជ្ជមាន

- ការទាញយកផលពីធនធាននៅមូលដ្ឋាន
- ហេដ្ឋារចនាសម្ព័ន្ធ និងការងារសាងសង់

### ឥទ្ធិពលអវិជ្ជមាន

- ធ្វើឱ្យខូចរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍ជាម្ចាស់ទីតាំងរ៉ែ
- រំខានដល់បូរណភាពដែនដីនៅមូលដ្ឋាន
- ធ្វើឱ្យគម្លាតខាងទ្រព្យសម្បត្តិកាន់តែធំធេង
- មានការងារតែមួយចំនួនតូចសម្រាប់ប្រជាជនមូលដ្ឋាន និង
- រេចរឹលបរិស្ថាននៅមូលដ្ឋាន ដែលសហគមន៍ពឹងផ្អែកសម្រាប់ការចិញ្ចឹមជីវិត

# ឥទ្ធិពលសង្គមនៃអាជីវកម្មរ៉ែ

- ការហូរចូលនៃប្រជាជន និងការពង្រីកទីក្រុង – ទីប្រជុំជន 'រីកធំ' ។ ប្រជាជនមូលដ្ឋានមានអារម្មណ៍មិនពេញចិត្តចំពោះជនចំណាកស្រុក ដោយសារ តាមធម្មតាអ្នកមកពីក្រៅមានប្រាក់ច្រើន និងមានអំណាចខ្ពស់ជាងអ្នកនៅមូលដ្ឋាន
- ឥទ្ធិពលសង្គម រួមមាន :
  - ការបាក់បែកក្នុងសហគមន៍ ការរំខានដល់ជីវភាពគ្រួសារ កំណើនការប្រើប្រាស់ គ្រឿងញៀន ការប្រព្រឹត្តល្បែង ចោរកម្ម ការនាំចូលអាវុធ
  - ការបាត់បង់តួនាទី និងឋានានុក្រមរបស់ស្ត្រី ពេស្យាចារ្យ និងជម្ងឺឆ្លងតាមផ្លូវភេទ (អេដស៍)
- ឥទ្ធិពលអវិជ្ជមានភាគច្រើន បង្កជាបន្ទុកលើស្ត្រី
- សហគមន៍ដែលនៅដាច់តែឯង ទំនងជាប្រឈមការបាត់បង់អំណាចត្រួតត្រាការចាត់ចែង និងសន្តិសុខក្នុងការរស់នៅរបស់ពួកគេ

# អភិបាលកិច្ចរ៉ែ

- ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ អភិបាលកិច្ចរ៉ែ បទប្បញ្ញត្តិ និងការត្រួតត្រាក្នុងសង្គម មានកម្រិតទាបនៅឡើយ
- ច្បាប់ចាស់ហួសសម័យ ដែលបានបង្កើតឡើងតាំងពីសម័យកាលអាណានិគម ពុំមានច្បាប់គ្រប់គ្រាន់ ច្បាប់សាំញ៉ាំ ច្បាប់ដែលមិនឆ្លុះបញ្ចាំងអំពីគុណតម្លៃសម័យនេះ ដូចជា សិទ្ធិមនុស្ស ឬគោលការណ៍ជួយដល់អ្នកក្រីក្រ
  - CBAA & និងដីធ្លីជនជាតិដើម
  - ច្បាប់ស្តីពីការទទួលបានដីធ្លី
  - កិច្ចព្រមព្រៀងសម្បទាន សម្រាប់ករណីនីមួយៗ
- កំណែទម្រង់ច្បាប់រ៉ែ ដើម្បីកំហិត និងសម្រួលឱ្យមានការផ្លាស់ប្តូរស្របតាមសម័យកាល
- មានកិច្ចការជាច្រើនដែលត្រូវធ្វើ ដើម្បីការពារប្រជាជនក្រីក្រ ដែលមានជំនាញតិចតួច និងមិនសូវបានទទួលការបណ្តុះបណ្តាល

THE AUSTRALIAN NATIONAL UNIVERSITY

# ទំនាក់ទំនងរបស់ពលរដ្ឋក្រីក្រជាមួយដីធ្លី

- *កង្វល់ចំនួនបួន* :
  - សិទ្ធិទទួលបានកម្មសិទ្ធិ និងការត្រួតត្រាលើចំណែកដី
  - សិទ្ធិស្វ័យសម្រេច តាមរយៈការឯកភាពដោយយល់ដឹងជាមុន ការចូលរួម និងការពាក់ព័ន្ធ
  - សិទ្ធិធ្វើជាតំណាងដោយខ្លួនឯង តាមរយៈស្ថាប័នរបស់ខ្លួនផ្ទាល់ និង
  - សិទ្ធិក្នុងការមានសន្តិសុខស្បៀង
- ត្រូវការឱ្យមានការយល់ដឹងបានស៊ីជម្រៅអំពីកត្តាសង្គម និងវប្បធម៌
- ដីធ្លី មិនមែនសម្រាប់តែការចិញ្ចឹមក្រពះប៉ុណ្ណោះ ប៉ុន្តែជាផ្នែកមួយនៃអត្តសញ្ញាណ
- ភាពជាម្ចាស់លើដីធ្លី តាមរបៀប "លោកខាងលិច" អាចមិនសមស្របក្នុងបរិបទអាស៊ី
- របៀបរស់នៅ : ទន្លេធំៗប្តូរលំនាំផ្លូវទឹក និងបង្កើត និងបំផ្លាញចំណែកដី តាមធម្មជាតិរបស់វា ហើយប្រជាជន ចេញ-ចូលក្នុងតំបន់នេះជាធម្មតា
- ចំណាកស្រុក និងការតាំងទីលំនៅថ្មី ដោយសារការធ្វើអាជីវកម្មរ៉ែ (MIDR)
  - ច្រើនជាង ៣ លាននាក់ នៅឥណ្ឌា ក្នុងនោះ 40% នៃជនចំណាកស្រុក គឺជាជនជាតិដើមភាគតិច

# អាជ្ញាប័ណ្ណសង្គមសម្រាប់ប្រតិបត្តិការ

## គោលគំនិតអំពី : ក្រៅច្បាប់ អរូបិយ និង ងាយប្រែប្រួល

ការទទួលស្គាល់ និងការទទួលយកនូវវិភាគទានពីឧស្សាហកម្មនេះ នៅក្នុងសហគមន៍ ដែលជាកន្លែងឧស្សាហកម្មនេះប្រតិបត្តិការ ទន្ទឹមនឹងឈានទៅហួសពីការបំពេញបានតាមលក្ខខណ្ឌសំខាន់ៗខាងផ្នែកច្បាប់ ឆ្ពោះទៅបង្កើត និង រក្សាឱ្យមានទំនាក់ទំនងប្រកបដោយការស្វាបនាជាមួយអ្នកពាក់ព័ន្ធនានា ដែលចាំបាច់សម្រាប់ធ្វើឱ្យអាជីវកម្មមាននិរន្តរភាព។ ជារួម វាកើតចេញពីការប្រឹងប្រែងដើម្បីបង្កើតឱ្យមានទំនាក់ទំនងដោយផ្អែកលើភាពស្មោះត្រង់ និងការគោរពគ្នាទៅវិញទៅមក។

មកទល់បច្ចុប្បន្ន ច្រើនតែនៅក្រៅ "កិច្ចការស្នូលនៃជំនួញ" ក្នុងអាជីវកម្មរ៉ែ ប៉ុន្តែមានការប្រែប្រួលជាសំខាន់ នូវទម្រង់ដែលក្រុមហ៊ុនរ៉ែប្រតិបត្តិការ

វាមានន័យថា សង្គមអាចតាមដាន និងវាស់ប្រសិទ្ធិភាពនៃគម្រោងមួយ និងដំណើរការរបស់ក្រុមហ៊ុនណាមួយ នៅទូទាំងវដ្តនៃគម្រោងនោះ។

ANU
THE AUSTRALIAN NATIONAL UNIVERSITY

# តើអាជីវកម្មរ៉ែជាអ្វី
# (តាមរយៈចក្ខុវិស័យរបស់ប្រជាពលរដ្ឋ)?

- មិនមែនត្រឹមតែសម្រាប់អង្គភាពអាជីវកម្មមួយ ដែលមានដើមទុនជារបស់ឯកជន ឬ សាធារណៈ ដែលប្រតិបត្តិការតាមរយៈបច្ចេកវិទ្យាទំនើប ជាទ្រង់ទ្រាយធំប៉ុណ្ណោះទេ
- ប្រជាជនមានចំនួនតូចតិចជាង នៅក្នុងអាជីវកម្មរ៉ែដោយគ្រឿងចក្រ - ត្រឹមតែ 1% នៃកម្លាំងពលកម្មសរុបលើពិភពលោក
- ប្រវត្តិយូរអង្វែង -សម័យកាលទង់ដែង រហូតដល់ លង្ហិន និងដែក ប៉ុន្តែមាស និងត្បូងថ្មផងដែរ។ ការធ្វើអាជីវកម្មរ៉ែជាលក្ខណៈសិប្បកម្ម - មានមនុស្សច្រើនជាងបានចូលរួម
- ការធ្វើអាជីវកម្មរ៉ែតាមវិធីទំនើប - ដោយអាណានិគមនិយមនៅអាស៊ី ដែលនាំឱ្យមានការអភិវឌ្ឍសកម្មភាពយករ៉ែនៅ "ដោយដុំ"
  - ត្បូងថ្មនៅឥណ្ឌា អាណានិគមចក្រភពអង់គ្លេសនៅម៉ាឡាយ៉ា និងអាណានិគមហូឡង់នៅឥណ្ឌូនេស៊ី គឺជាអ្នកផលិតសំណប៉ាហាំងធំជាងគេលើពិភពលោក និងត្បូងថ្មពីអាណានិគម បារាំងនៅវៀតណាម
- ការយករ៉ែដោយបង្ខំចិត្ត ដោយសារភាពក្រីក្រ និងការប្រជែងគ្នា គឺជាវិស័យមិនផ្លូវការ ជាការទាញយករ៉ែល្មើសច្បាប់ ដើម្បីទាញយកប្រយោជន៍ពីថ្លៃខ្ពស់នៃផលិតផលនេះ

# ប្រជាជន ដែលផ្សំដោយស្ត្រី និងបុរស

## ស្ត្រីនៅក្នុងផលិតកម្មរ៉ែ

- ជាកម្មករនៅក្នុងផលិតកម្មរ៉ែមុនសម័យឧស្សាហកម្ម (ផ្នែកមួយនៃពលកម្មជាគ្រួសារ)
  - បំបែក និងស្រាស់រ៉ែឆៅ អូសរទេះ និងដឹកជញ្ជូន រំលាយ និងកែច្នៃ ធ្វើការជាមួយប្រដាប់លើកដាក់
- វីកល្វូតលាស់នៅក្នុងឧស្សាហកម្មរ៉ែសម័យទំនើប  នៅទូទាំងអឺរ៉ុប
  - ក្នុងអណ្តូងធ្យូងថ្ម និងរ៉ែអំបិល នៅឥណ្ឌា និងប៉ាគីស្ថង់
  - ប្រទេសនានានៅអាស៊ី — ជប៉ុន ម៉ាឡេ
- ត្រូវសម្រួលឱ្យមានការផ្តល់ការងារសម្រាប់ស្ត្រី
- នៅក្នុង ASM ជាចំនួនច្រើន — សកម្មភាពក្នុងវិស័យក្រៅប្រព័ន្ធ
- ស្ត្រីពុំមានកម្មសិទ្ធិជាដីធ្លី/អណ្តូងរ៉ែឡើយ

## ស្ត្រី និងរ៉ែ

- ជាទូទៅ ឥទ្ធិពលលើស្ត្រីមានលក្ខណៈអវិជ្ជមាន - បុរសបានទទួលការទូទាត់ជាប្រាក់កម្រៃ ចរចាមានការងារធ្វើ

# ប្រជាជននៅក្នុងវដ្តគម្រោង

- **ការរុករក** – ការកសាងផែនការផ្នែកសង្គម ទម្រង់នៃការចិញ្ចឹមជីវិត យុទ្ធសាស្ត្រទប់ទល់ កម្មសិទ្ធិលើធនធាន ឌីណាមិកនៃអំណាចក្នុងចំណោមក្រុមមានប្រាក់ចំណូលខុសៗគ្នា ជនជាតិនិងយេនឌ័រ
- **ការវាយតម្លៃកំណប់រ៉ែ**– ការពិគ្រោះយោបល់ ដោយឱ្យមាន "ការឯកភាព និងតាមរយៈការដឹងឮជាមុន" ការចាប់ផ្តើមធ្វើឱ្យសហគមន៍ពាក់ព័ន្ធ - ស្ត្រីត្រូវតែជាផ្នែកមួយ ការវិភាគយេនឌ័រ - តួនាទីរបស់ស្ត្រី និងបុរស
- **ការកសាងផែនការអណ្តូងរ៉ែ** - ការវាយតម្លៃហេតុប៉ះពាល់សង្គម ការអង្កេតផែនទីសង្គម ការវាយតម្លៃហេតុប៉ះពាល់វប្បធម៌ និងការកសាងផែនការ R&R
- **ការសាងសង់** – ការអភិវឌ្ឍសហគមន៍ ចាប់ផ្តើមដោយការអង្កេតតម្រូវការរបស់សហគមន៍ (បុរស និងស្ត្រី មានតម្រូវការដាច់ដោយឡែកពីគ្នា)
- **ប្រតិបត្តិការអណ្តូងរ៉ែ** - គម្រោងអំពីរបរចិញ្ចឹមជីវិត ការបណ្តុះបណ្តាល និងអប់រំ ឥណទានសម្រាប់បង្កើតជំនួញខ្នាតតូច និងសកម្មភាពដែលផ្តល់ប្រាក់ចំណូល
- **ការបិទការដ្ឋានអណ្តូងរ៉ែ** – ការពិគ្រោះយោបល់សហគមន៍ និងគម្រោងរបរចិញ្ចឹមជីវិត



# អរគុណច្រើន!

អាសយដ្ឋានទាក់ទង: kuntala.lahiri-dutt@anu.edu.au